YUNNAN DAILY PRESS GROUP
No.143

# ប្រទេសចិន-ខេត្តយូនណាន

រស្មីកម្ពុជា ប្រចាំថ្ងៃ

YUNNAN DAILY PRESS GROUP
english.yunnan.cn

ឆ្នាំទី 26 លេខ 7557 ថ្ងៃសុក្រ ទី 09 ខែ កុម្ភៈ ឆ្នាំ 2018

## អភិបាលខេត្តយូនណានថា "ដើរលេងខេត្តយូនណានដោយប្រើទូរស័ព្ទតែមួយគ្រឿង"



*លោកយាន់ ឈឹងហ្វាអភិបាលខេត្តយូនណាន បានអញ្ជើញចូលរួមក្នុងសន្និសីទអ្នកកាសែត ដែលរៀបចំ កាលពីថ្ងៃទី៣១ ខែ មករា (រូបថតដោយ Sun Xiaoyun )*

យូនណានជាខេត្តល្បីឈ្មោះខាងទេសចរណ៍ក្នុងប្រទេសចិន ។ ពេលថ្មីៗនេះ ក្នុងគោលបំណងជំរុញការអភិវឌ្ឍវិស័យទេសចរណ៍ដែលមានលក្ខណៈវៃឆ្លាត លោក យាន់-ឈឹងហ្វា អភិបាលខេត្តយូនណាន បានអញ្ជើញចូលរួមក្នុងសន្និសីទអ្នកកាសែត ហើយបានបកស្រាយអំពី"កម្មវិធីដើរលេងខេត្តយូនណានដោយប្រើទូរស័ព្ទតែមួយគ្រឿង"និងបានឆ្លើយសំណួររបស់អ្នកសារព័ត៌មានជាតិ និងអន្តរជាតិ ។ ពេលនេះយើងខ្ញុំសូមណែនាំអំពីការបក-ស្រាយរបស់លោកអភិបាល ខេត្តយូន-ណាន ដើម្បីធ្វើឱ្យលោកអ្នកមានការយល់ដឹងកាន់តែច្រើនអំពីទស្សនៈ និងការអនុវត្ត"កម្មវិធីដើរលេងខេត្តយូនណានដោយប្រើទូរស័ព្ទតែមួយគ្រឿង" នេះ ។

លោកអភិបាលខេត្តបានមានប្រសាសន៍ថា តើយើងត្រូវធ្វើយ៉ាងម៉េចដើម្បីជំរុញការផ្លាស់ទម្រង់នៃការអភិវឌ្ឍឧស្សាហកម្មទេសចរណ៍ ? តាមរយៈការអនុវត្តជាក់ស្តែងយើងខ្ញុំបានទទួលបទពិសោធន៍ថា ចាំបាច់ត្រូវតែច្របាច់បញ្ចូលគ្នានូវវិស័យទេសចរណ៍ និងបណ្តាញអ៊ីនធើណេត ដើម្បីជំរុញការអភិវឌ្ឍវិស័យទេសចរណ៍ដែលមានលក្ខណៈវៃឆ្លាត ។ "កម្មវិធីដើរលេងខេត្តយូនណានដោយប្រើទូរស័ព្ទតែមួយគ្រឿង"គឺជាកម្មវិធី APP មួយដែលស្របទៅនឹងនិន្នាការអភិវឌ្ឍនៃបច្ចេកទេសឌីជីថល និងព័ត៌មានវិទ្យា ។

ខេត្តយូនណាននឹងខិតខំជំរុញការអភិវឌ្ឍវិស័យទេសចរណ៍ដែលមានលក្ខណៈវៃឆ្លាតតាមរយៈការប្រើប្រាស់បច្ចេកទេសទំនើបគ្រប់ប្រភេទ រួមមាន"បណ្តាញអ៊ីនធើណេត "Big Data" "Cloud Computing" និង"Artificial Intel-ligence" ។ល។

ក្រោយពីអនុវត្តន៍"កម្មវិធីដើរលេងខេត្តយូនណានដោយប្រើទូរស័ព្ទតែមួយគ្រឿង" អ្នកទេសចរដែលអញ្ជើញមកដើរលេងខេត្តយូនណានអាចទទួលបាននូវសេវាកម្មពេញលក្ខណៈគ្រប់ប្រភេទ រួមមានការហូបចុក ស្នាក់នៅ ធ្វើដំណើរ ដើរលេង ទិញទំនិញ និងការលេងកម្សាន្តជាដើម ដើម្បីធ្វើទេសចរដោយមានភាពសប្បាយរីករាយ និងភាពរលូននៅខេត្តយូន-ណាន ។ ឧទាហរណ៍អ្នកទេសចរអាចទិញសំបុត្រតាមកម្មវិធី APP ក្នុងទូរស័ព្ទ ហើយចូលក្នុងតំបន់ទេសចរណ៍ដោយ"ស្កេនមុខ"តែម្តង ។ មិនតែប៉ុណ្ណោះ ពួកគេក៏អាចបង់ថ្លៃនៃការធ្វើដំណើរតាមផ្លូវល្បឿនលឿន ស្តាប់ការឧទ្ទេសនាមអំពីតំបន់ទេសចរណ៍ ទារយកវិក្កយបត្រយអេឡិចត្រូនិក កុម្ម៉ង់ម្ហូប រកបន្ទប់ទឹក ទិញផលិតផលពិសេសខេត្តយូនណាន ដោយប្រើប្រាស់ប្រព័ន្ធកម្មវិធី APP ក្នុងទូរស័ព្ទ ។

កម្មវិធី APP ក្នុងទូរស័ព្ទអំពី"ការដើរលេងខេត្តយូនណានដោយប្រើទូរស័ព្ទតែមួយគ្រឿង"នេះមានផ្នែកសំខាន់៣ ពោលគឺមានមជ្ឈមណ្ឌលមួយ និងវេទិកាពីរ ។ មជ្ឈមណ្ឌលនោះគឺមជ្ឈមណ្ឌល Big Data អំពីវិស័យទេសចរណ៍ ដែលជាប្រព័ន្ធសម្រាប់ប្រមូលវិភាគនិងប្រើប្រាស់ទិន្នន័យទេសចរណ៍ ។ ចំណែកវេទិកាទាំងពីរនោះ គឺវេទិកាផ្តល់សេវាកម្មដល់អ្នកទេសចរ និងវេទិកាគ្រប់គ្រងវិស័យទេសចរណ៍សម្រាប់ផ្តល់សេវាកម្មគ្រប់ប្រភេទ និងការងាយស្រួលដល់អ្នកទេសចរដែលធ្វើទេសចរនៅខេត្តយូនណាន ព្រមទាំងដោះស្រាយបញ្ហាបន្ទាន់ផ្សេងៗ និងបំពេញតម្រូវការរបស់អ្នកទេសចរដើម្បីធ្វើឱ្យទេសចរទទួលអារម្មណ៍អំពីការគ្រង់គ្រង និងសេវា-កម្ម ដែលផ្តល់ដោយ រដ្ឋាភិបាលចិន ។ "កម្មវិធីដើរលេងខេត្តយូនណានដោយប្រើទូរស័ព្ទតែមួយគ្រឿង"បានទទួលលទ្ធផលជាក់ស្តែងគួរឱ្យកត់សម្គាល់ ដែលជាគម្រោង និងប្រព័ន្ធដ៏ល្អមួយសម្រាប់បង្កើតជាប្រព័ន្ធទេសចរណ៍ដែលមានលក្ខណៈវៃឆ្លាតនៅខេត្ត-យូនណាន ៕ **ដោយ លី សាវម៉េង**

## កម្មវិធីទូរទស្សន៍បារាំងផ្សព្វផ្សាយអំពីផ្លូវបុរាណតែ និងសេះរបស់ខេត្តយូនណាន

យប់ថ្ងៃទី២៣ ខែមករា ឆ្នាំ២០១៨ ពិធីចាក់ផ្សាយជាលើកដំបូងនូវកម្មវិធីទូរទស្សន៍បារាំង "ទីអាថ៌-កំបាំងៈ ផ្លូវបុរាណតែ និងសេះ" បានត្រូវរៀបចំឡើងនៅស្ថានទូតប្រទេសចិនប្រចាំនៅប្រទេសបារាំង ។ កម្មវិធីទូរទស្សន៍នេះឧទ្ទេសនាមអំពីប្រវត្តិ-សាស្ត្រ វប្បធម៌ និងទំនៀមទម្លាប់ប្រពៃណីតាមផ្លូវបុរាណតែ និងសេះរបស់ខេត្តយូនណានប្រទេសចិន ។

លោក តាណា អាសជា អ្នកទទួលខុសត្រូវនៃប៉ុស្តិ៍លេខ៣ ស្ថានីយទូរទស្សន៍បារាំងបានថ្លែងសុន្ទរកថាក្នុងពិធីនេះថា កម្មវិធីទូរទស្សន៍នេះបានឧទ្ទេសនាមអំពីផ្លូវបុរាណតែ និងសេះរបស់ប្រទេសចិន ហើយនឹងអាចធ្វើឱ្យទស្សនិកជនមានការស្វែងយល់កាន់តែស៊ីជម្រៅអំពីទេសភាពធម្មជាតិដ៏ស្រស់ស្អាត ប្រវត្តិសាស្ត្រដ៏យូរអង្វែង វប្បធម៌ដ៏ក្រាស់ក្រែល និងទំនៀម-ទម្លាប់ដ៏ចម្រុះពណ៌របស់ប្រទេសចិន ។

តាមការឧទ្ទេសនាមបានឱ្យដឹងថា ផ្លូវបុរាណតែ និងសេះគឺជាច្រកផ្លូវដ៏សំខាន់មួយនៅសម័យបុរាណចិនសម្រាប់ធ្វើដំណើរពីភូមិភាគនិរតីចិនទៅកាន់តំបន់អាស៊ីអាគ្នេយ៍ អាស៊ីខាងត្បូង និងអាស៊ីខាងលិច ។ ផ្លូវបុរាណតែនិងសេះ និងផ្លូវសូត្របុរាណមានលក្ខណៈស្រដៀងគ្នា ដែលសុទ្ធតែជាផ្លូវសំខាន់សម្រាប់រក្សាការផ្លាស់ប្តូរផ្នែកសេដ្ឋកិច្ច និងវប្បធម៌រវាងប្រទេសចិន និងប្រទេសជិតខាងនានានៅសម័យបុរាណ ៕ **(ស៊ិនហួចិន)**

## សហគ្រាសចិនផ្តល់ជំនួយសាងសង់ផ្លូវឱ្យសាលារៀន និងសិស្សខ្មែរ

ថ្ងៃទី ២៨ ខែមករា ឆ្នាំ ២០១៨ គឺជាថ្ងៃដ៏សំខាន់ និងពិសេសសម្រាប់សាលាក្លួនហ្លួងនៅស្រុកស្នួលខេត្តក្រចេះនៃប្រទេសកម្ពុជា ។ ផ្លូវស៊ីម៉ងត៍ថ្មីមួយខ្សែបានត្រូវសាងសង់ និងដាក់ឱ្យប្រើប្រាស់ជាផ្លូវការនៅស្រុកស្នួល ។ ផ្លូវថ្មីនេះបានតភ្ជាប់សាលានេះទៅនឹងផ្លូវសំខាន់ក្នុងស្រុកខាងលើ ដែលនឹងអាចធ្វើឱ្យសិស្សសាលានេះធ្វើដំណើរដោយមានសុវត្ថិភាពជារៀងរាល់ថ្ងៃ ។

គួរបញ្ជាក់ថា ផ្លូវថ្មីដែលមានប្រវែងរាប់រយម៉ែត្រនេះ សាងសង់ដោយធនាគារចិនសាខាភ្នំពេញ (ហុងកុង) និងក្រុមហ៊ុនផលិតស៊ីម៉ងត៍ហួរស៊ីននៅកម្ពុជា ដើម្បីបំពេញភារកិច្ចសប្បុរសធម៌ក្នុងសង្គមខ្មែរ និងចូលរួមចំណែកក្នុងការអភិវឌ្ឍន៍នៃបុព្វហេតុអប់រំនៅប្រទេសកម្ពុជា ។

លោកនាយកសាលាបានប្រាប់អ្នកកាសែតថា សាលានេះត្រូវបានបង្កើតឡើងនៅឆ្នាំ ២០១១ ក៏ប៉ុន្តែសាលាខ្វះថវិកាជួសជុលផ្លូវនៅមុខសាលានោះទេ។ ផ្លូវថ្មីនេះជាផ្លូវជម្រាលដែលតែងតែមានធូលីហុយទ្រលោមនៅរដូវប្រាំង និងរអិលខ្លាំងនៅរដូវវស្សា ពិតជាពិបាកធ្វើដំណើរ និងតែងតែកើតមានគ្រោះថ្នាក់សម្រាប់សិស្សចូលរៀន ។ លោកនាយកសាលាបានបញ្ជាក់ទៀតថា ជំនួយរបស់សហគ្រាសចិនបានផ្តល់ផ្លូវសុវត្ថិភាពមួយខ្សែដល់សិស្សគ្រប់ៗគ្នា ហើយក៏បានកែលម្អបរិស្ថានជុំវិញសាលារៀនដែរ ៕

**ដោយ ម៉ាវ ភឹងហ្វី (ស៊ិនហួចិន)**

## ប្រទេសចិនទទួលលទ្ធផលជាផ្លែផ្កាក្នុងការកាត់បន្ថយភាពក្រីក្រ



*នៅខេត្តស្វ័យយ័ត នៃមណ្ឌលស្វយ័តជនជាតិអ៊ី ដែលស្ថិតនៅភាគកណ្តាល នៃខេត្តយូនណា ប្រទេសចិន កំពុងតែ ក្លាយជាតំបន់ឧស្សាហកម្ម និងបានដើរតួនាទីយ៉ាងសំខាន់ សម្រាប់កាត់ បន្ថយ ភាពក្រីក្រ (រូបថតដោយ Li Qiuming )*

ក្នុងអំឡុងពេល ៤០ ឆ្នាំបន្ទាប់ពីបានអនុវត្តន៍គោលនយោបាយកែទម្រង់ និងបើកទ្វារចំហប្រទេសចិនបានកាត់បន្ថយភាពក្រីក្រឱ្យប្រជាជនចិនជាង ៧០០លាននាក់ ។ ជាពិសេស ក្រោយពីសមាជបក្សកុម្មុយនិស្តចិនលើកទី ១៨ រៀងមក ប្រទេសចិនបានទទួលសមិទ្ធផលសំខាន់ក្នុងការកាត់បន្ថយភាពក្រីក្រ ដែលបានធ្វើឱ្យប្រជាជនជាង ៦០ លាននាក់ជៀសផុតពីភាពក្រីក្រ និងបានធ្វើឱ្យអត្រាប្រជាជនក្រីក្រធ្លាក់ចុះពី ១០,២ ភាគរយ ដល់ទៅក្រោម ៤ភាគរយ ហើយបានទទួលនូវការវាយតម្លៃខ្ពស់ពីបណ្តាប្រទេសនានាលើពិភពលោក ។ អង្គសមាជបក្សកុម្មុយនិស្តចិនលើកទី ១៩ បានលើកឡើងថា នៅឆ្នាំ ២០២០ ប្រទេសចិននឹងកាត់បន្ថយភាពក្រីក្រឱ្យប្រជាជនចិនគ្រប់ៗគ្នាដែលរស់នៅក្នុងតំបន់ជនបទ និងធ្វើឱ្យស្រុកក្រីក្រទាំងអស់ជៀសផុតពីភាពក្រីក្រទាំងស្រុង ។

បច្ចុប្បន្ននៅលើពិភពលោកយើងនៅមានប្រជាជនក្រីក្រ៧០០ លាននាក់ ដូច្នេះសហគមន៍អន្តរជាតិចាប់អារម្មណ៍យ៉ាងខ្លាំងចំពោះបទពិសោធន៍របស់ប្រទេសចិនក្នុងការកាត់បន្ថយភាពក្រីក្រ ។ អ្នកជំនាញការបរទេសបានប្រាប់អ្នកកាសែតថា ប្រទេសចិនបានទទួលសមិទ្ធផលច្រើនគួរឱ្យកត់សម្គាល់ក្នុងការកាត់បន្ថយភាពក្រីក្រ ដែលកំពុងតែដើរតួនាទីនាំមុខគេក្នុងការកាត់បន្ថយភាពក្រីក្រលើពិភពលោក ។

លោកស្រី អានណា ខានពួស៍ អ្នកទទួលខុសត្រូវចំពោះគម្រោងអំពីការកាត់បន្ថយភាពក្រីក្រអង្គការស្បៀងអាហារ និងកសិកម្មនៃអង្គការសហប្រជាជាតិបានបញ្ជាក់ថា ប្រទេសចិនបានទទួលលទ្ធផលជាផ្លែផ្កាក្នុងការកាត់បន្ថយភាពក្រីក្រ ពីព្រោះរដ្ឋាភិបាលចិនតែងតែផ្តោតការយកចិត្តទុកដាក់ទៅលើការកាត់បន្ថយភាពក្រីក្រ និងបានកំណត់គោលដៅច្បាស់-លាស់អំពីការកាត់បន្ថយភាពក្រីក្រ ។

លោក ដោន ណែសពីត អ្នកសិក្សាស្រាវជ្រាវអនាគតកាល និងជាអ្នកនិពន្ធល្បីឈ្មោះនៅប្រទេសអាមេរិកបានផ្តល់បទសម្ភាសន៍ជាមួយអ្នកកាសែតថា កិច្ចខិតខំប្រឹងប្រែងរបស់ប្រទេសចិនក្នុងការកាត់បន្ថយភាពក្រីក្រពិតជាមានសារសំខាន់ណាស់សម្រាប់ជាបទពិសោធន៍របស់សេដ្ឋកិច្ចដែលទើបកើតជាថ្មីលើពិភពលោក ។

លោក គូសៀហ្វ អ្នកសិក្សាស្រាវជ្រាវជាន់ខ្ពស់នៃមជ្ឈមណ្ឌលវិភាគ និងសិក្សាស្រាវជ្រាវនៃមហា-វិទ្យាល័យសិក្សាស្រាវជ្រាវទំនាក់ទំនងអន្តរជាតិម៉ូស្គូប្រទេសរុស្ស៊ីបានគូសបញ្ជាក់ថា ការកាត់បន្ថយភាពក្រីក្រនឹងអាចធ្វើឱ្យប្រទេសចិនក្លាយទៅជាទីផ្សារកាន់តែធំទូលាយ ហើយនឹងនាំមកនូវកម្លាំងរស់រវើកកាន់តែច្រើនសម្រាប់ជំរុញការអភិវឌ្ឍសេដ្ឋកិច្ចពិភពលោក ។ បទពិសោធន៍របស់ប្រទេសចិននឹងអាចផ្តល់ផលប្រយោជន៍ដ៏មានតម្លៃដល់បណ្តាប្រទេសកំពុងអភិវឌ្ឍន៍ ។

លោកសាស្ត្រាចារ្យ ខាម៉ាស៊ី ដែលមកពីសាកលវិទ្យាល័យសៀម៉ាល់ប្រទេសឥណ្ឌាបានលើកមតិថា បើតាមផែនការអំពីការកាត់បន្ថយភាពក្រីក្រដែលកំណត់ដោយរដ្ឋាភិបាលចិន ប្រទេសចិននឹងកាត់បន្ថយភាពក្រីក្រទាំងស្រុងនៅឆ្នាំ២០២០ ។ សមិទ្ធផលនេះមិនគ្រាន់តែជាជោគជ័យដ៏ធំធេងនៃការកាត់បន្ថយភាពក្រីក្ររបស់ប្រទេសចិនប៉ុណ្ណោះទេ ហើយក៏ជាការរួមវិភាគទានដ៏សំខាន់របស់ប្រទេសចិនក្នុងការអភិវឌ្ឍនៃសង្គមមនុស្សជាតិផងដែរ ។ ប្រទេសចិនជាគំរូរបស់ប្រទេសទាំងអស់លើពិភពលោក រួមមានប្រទេសកំពុងអភិវឌ្ឍន៍ និងប្រទេសអភិវឌ្ឍន៍ ។ នេះក៏ជាសារសំខាន់នៃគម្រោងចិន និងទស្សនៈរបស់ប្រទេសចិនផងដែរ ៕

**(កាសែតប្រជាជន ដេលី)**

## សកម្មភាពធ្វើដំណើរតាមពេលកំណត់ដែលមានទ្រង់ទ្រាយធំជាងគេលើពិភពលោក



*កាលពីពេលថ្មីៗនេះ និស្សិត អន្តរជាតិបីរូប បានស្ម័គ្រចិត្តផ្តល់ សេវាកម្មដល់អ្នកដំណើរនៅលើ រថភ្លើងល្បឿនលឿនមួយគ្រឿង ដែលចេញដំណើរពីស៊ីអានទៅធីងទូ ដើម្បី ដកស្រង់បទពិសោធន៍នៅអំឡុងថ្ងៃ សម្រាកចូលឆ្នាំថ្មីប្រពៃណីជនជាតិចិន ។ នេះគឺជាទិដ្ឋភាពដែលពួកគេកំពុងតែ ផ្តល់សេវាកម្មដល់អ្នកដំណើរចាស់ៗ (រូបថតស៊ីនហួរ ដោយ Tang Zhenjiang )*

នៅថ្ងៃទី១ ខែកុម្ភៈ ឆ្នាំ ២០១៨ "សកម្មភាពធ្វើដំណើរនៅបុណ្យចូលឆ្នាំចិន" បានចាប់ដំណើរការជាផ្លូវការ ហើយនឹងបញ្ចប់នៅថ្ងៃទី១២ ខែមីនា ឆ្នាំ ២០១៨ ។ "សកម្មភាពធ្វើដំណើរនៅបុណ្យចូលឆ្នាំចិន" បានត្រូវគេដាក់ឈ្មោះថា "សកម្មភាពធ្វើដំណើរតាមពេលកំណត់ដែលមានទ្រង់ទ្រាយធំជាងគេរបស់មនុស្សជាតិលើពិភព-លោក" ។ តាមប្រភពព័ត៌មានបានឱ្យដឹងថា ក្នុងឱកាសបុណ្យចូលឆ្នាំចិននេះនឹងមានអ្នកដំណើរ២៩៨០លាននាក់ធ្វើដំណើរទៅមកនៅប្រទេសចិនដែលមានទ្រង់ទ្រាយប្រហាក់ប្រហែលគ្នានឹងឆ្នាំមុន ។ ក្នុងនោះ ចំនួនអ្នកដំណើរ ដែលធ្វើដំណើរតាមរថភ្លើង និងយន្តហោះបានកើនឡើង ៨,៨ ភាគរយ និង១០ភាគរយរៀងខ្លួន ចំណែកអ្នកដំណើរដែលជិះឡានបានធ្លាក់ចុះ១,៦ភាគរយ ។ នេះជាលើកទី១ ដែលចំនួនអ្នកដំណើរធ្វើដំណើរដោយជិះឡានមានការធ្លាក់ចុះក្នុងរយៈពេលកន្លងមក ៕

**ដោយ យ៉ាន ពីង (កាសែតប្រជាជនដេលី បោះពុម្ពផ្សាយនៅឯនាយសមុទ្រ)**